ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ

លេខ ០២៤ ប្រក កសក

# ប្រកាស

## ស្តីពី

## បទបញ្ញាបច្ចេកទេសនៃការគ្រប់គ្រងនាយទារនេសាទ

## រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៣ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៥០៦/០១១ ចុះថ្ងៃទី ២១ ខែ ឧសភា ឆ្នាំ២០០៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីជលផល
- បានឃើញអនុក្រឹត្យលេខ ១៧ អនក្រ.បក ចុះថ្ងៃទី ០៧ ខែ មេសា ឆ្នាំ ២០០០ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
- បានឃើញអនុក្រឹត្យលេខ ១៨៨ អនក្រ.បក ចុះថ្ងៃទី ១៤ ខែ វិច្ឆិកា ឆ្នាំ ២០០៨ ស្តីពីការកែសម្រួលអគ្គនាយកដ្ឋាននៃក្រសួងទៅជាអគ្គលេខាធិការដ្ឋាន ការដំឡើងរដ្ឋបាលព្រៃឈើ រដ្ឋបាលជលផលឱ្យមានថ្នាក់ស្មើអគ្គនាយកដ្ឋាន ការដំឡើងនាយកដ្ឋានកៅស៊ូ ... ការដំឡើងនាយកដ្ឋានក្សេត្រសាស្ត្រ និងកែលម្អដីកសិកម្មឱ្យទៅជាអគ្គនាយកដ្ឋានកសិកម្ម និងការកែសម្រួលអគ្គនាយកដ្ឋានចម្ការកៅស៊ូទៅជាអគ្គនាយកដ្ឋានកៅស៊ូ ស្ថិតក្រោមការគ្រប់គ្រងរបស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
- យោងតាមសំណើរបស់ប្រតិភូរាជរដ្ឋាភិបាលកម្ពុជា ទទួលបន្ទុកជា ប្រធានរដ្ឋបាលជលផល

អាស័យដ្ឋានលេខ២០០ មហាវិថីព្រះនរោត្តម សង្កាត់ទន្លេបាសាក់ ខណ្ឌចំការមន រាជធានីភ្នំពេញ កម្ពុជា
Nº.200 Preah Norodom Sangkat Tonle Basak Khan Chamkarmon B V D. Phnom Penh, Cambodia
ទូរស័ព្ទលេខ : (០២៣) ២១១ ៣៥១/២១១ ៣៥២ ទូរសារលេខ : (៨៥៥) ២៣-២១៧ ៣២០
Phone : (023) 211 351/211 352, Fax : (855) 23 – 217 320

# ស ម្រេ ច

**ប្រការ ១ :** ប្រកាសនេះមានគោលបំណងកំណត់នូវបទបញ្ញាបច្ចេកទេសនៃការគ្រប់គ្រងនាវានេសាទ ដើម្បីគ្រប់គ្រងនាវានេសាទដែលធ្វើអាជីវកម្មនេសាទនៅក្នុងដែននេសាទនៃព្រះរាជាណាចក្រកម្ពុជាឱ្យបានល្អ និងធានាសុវត្ថិភាព សុខមាលភាព អនាម័យ បរិស្ថាន សន្តិសុខ សណ្តាប់ធ្នាប់ចរាចរផ្លូវទឹក និងការការពារគ្រោះថ្នាក់អាយុជីវិតដល់អ្នកនេសាទអ្នករួមដំណើរ ព្រមទាំងទ្រព្យសម្បត្តិ និងមធ្យោបាយសម្រាប់ធ្វើអាជីវកម្មនេសាទ។

**ប្រការ ២ :** នាវានេសាទគ្រប់ប្រភេទមានចំណុះផ្ទុកលើសពី ៥០០ គ .ក្រ ដែលធ្វើអាជីវកម្មនេសាទនៅក្នុងដែននេសាទនៃព្រះរាជាណាចក្រកម្ពុជា ត្រូវគោរពតាមបទបញ្ញាបច្ចេកទេសនៃការគ្រប់គ្រងនាវានេសាទ ដើម្បីធានាសុវត្ថិភាព សណ្តាប់ធ្នាប់ចរាចរផ្លូវទឹក និងអាយុជីវិតអ្នកនេសាទ។

**ប្រការ ៣ :** នាវានេសាទទាំងអស់ ដូចមានចែងក្នុងប្រការ ២ ដែលធ្វើអាជីវកម្មនេសាទក្នុងដែននេសាទ ត្រូវបំពេញលក្ខខណ្ឌបច្ចេកទេស និងលក្ខខណ្ឌនៃការធ្វើនេសាទ ដូចខាងក្រោម :

**ក- <u>លក្ខខណ្ឌបច្ចេកទេសនាវានេសាទ ត្រូវមាន:</u>**

១-ដោតទង់ជាតិ នៃព្រះរាជាណាចក្រកម្ពុជា។

២-ស្លាកលេខសម្គាល់នាវា ភ្លើងសញ្ញា សញ្ញាសំគាល់។

៣-វិទ្យុទាក់ទង ឧបករណ៍ពន្លត់អគ្គីភ័យ ពោងសង្គ្រោះ អាវពោង កែវយឺត ត្រីវិស័យ ឬ GPS ថ្នាំពេទ្យសម្រាប់សង្គ្រោះបឋម ភ្លើងហ្វាសម្រាប់មើលផ្លូវ ភ្លើងសញ្ញាប្រកាសអាសន្ន ស៊ីប្លេ ឬជួង។

៤-សំបកនាវានេសាទ និងម៉ាស៊ីននាវានេសាទ ដែលមានគុណភាព និងសុវត្ថិភាពក្នុងការធ្វើអាជីវកម្មនេសាទ។

៥-ធុងសម្រាប់ផ្ទុករាល់កាកសំណល់នៅលើនាវានេសាទ និងប្រេងដែលបានប្តូរចេញពីម៉ាស៊ីនឱ្យបានត្រឹមត្រូវ ហើយត្រូវយកទៅចោលនៅទីកន្លែងដែលបានកំណត់។

៦-លាបពណ៌សម្គាល់នៅលើគែមនាវានេសាទ តាមរាជធានី ខេត្ត ដូចខាងក្រោម :

| ល.រ | រាជធានី-ខេត្ត | ពណ៌សម្គាល់ |
|---|---|---|
| ១ | រាជធានីភ្នំពេញ | ស |
| ២ | កណ្តាល | ក្រហម |
| ៣ | តាកែវ | ខៀវ |
| ៤ | ព្រៃវែង | បៃតង |
| ៥ | កំពង់ចាម | លឿង |
| ៦ | ក្រចេះ | ប្រផេះ |
| ៧ | ស្ទឹងត្រែង | ផ្ទៃមេឃ |
| ៨ | កំពង់ធំ | ផ្កាឈូក |

ស

| | | |
|---|---|---|
| ៩ | សៀមរាប | ឈាមជ្រូក |
| ១០ | បន្ទាយមានជ័យ | ខៀវខ្ចី |
| ១១ | បាត់ដំបង | ប្រាក់ |
| ១២ | ពោធិ៍សាត់ | ស្វាយ |
| ១៣ | កំពង់ឆ្នាំង | លឿងទុំ |
| ១៤ | កំពត | ក្រហម |
| ១៥ | កែប | ផ្កាឈូក |
| ១៦ | ព្រះសីហនុ | លឿង |
| ១៧ | កោះកុង | ស |

**ខ- <u>លក្ខខណ្ឌនៃការធ្វើនេសាទ ត្រូវ</u> :**

១-មានលិខិតអនុញ្ញាតឱ្យប្រើប្រាស់នាវានេសាទ និងសៀវភៅនាវានេសាទ ។

២-មានសៀវភៅកត់ត្រាស្ថិតិផល ផលិតផលជលផល ហើយមានការកត់ត្រាទៀងទាត់រៀងរាល់ថ្ងៃ ពេលធ្វើនេសាទ ។

៣-អនុវត្តតាមលក្ខខណ្ឌដែលមានចែងក្នុងសៀវភៅនាវានេសាទ ។

៤-រក្សាគុណភាព និងអនាម័យ ផល ផលិតផលជលផល ។

៥-ប្រើឧបករណ៍នេសាទស្របច្បាប់ តាមប្រកាសរបស់រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ។

៦-ប្រើភ្លើងសញ្ញា ឬសញ្ញាសម្គាល់ស្របតាមបទបញ្ញត្តិពីការគ្រប់គ្រងមធ្យោបាយដឹកជញ្ជូនតាមផ្លូវទឹកជាតិ និងអន្តរជាតិនៅពេលចូលសំចតខុសទីតាំង ។

**ប្រការ ៤** : អាជីវករនេសាទដែលរៀបចំនាវានេសាទគ្រប់ប្រភេទ និងតម្លើងសម្ភារៈបរិក្ខារ ឬឧបករណ៍នេសាទ ត្រូវសុំចុះបញ្ជីពីរដ្ឋបាលជលផលមានសមត្ថកិច្ច ដោយភ្ជាប់មកជាមួយនូវសំណុំលិខិតដូចខាងក្រោម :

១-ពាក្យស្នើសុំចំនួន ១ ច្បាប់ ដែលមានបិទតែមប្រ៍ ។

២-ប្លង់នាវានេសាទចំនួន ១ ច្បាប់ ។

៣-តារាងលំអិតសម្ភារៈដែលត្រូវប្រើប្រាស់ចំនួន ១ ច្បាប់ ។

៤-លិខិតបញ្ជាក់ទីលំនៅចំនួន ១ ច្បាប់ ។

អាជីវករនេសាទ ដែលមានបំណងប្តូរម៉ាស៊ីននាវានេសាទត្រូវសុំការអនុញ្ញាតពីរដ្ឋបាលជលផលមានសមត្ថកិច្ច ។

**ប្រការ ៥** : **ក**- អ្នកបើកបរនាវានេសាទទាំងអស់ ត្រូវមានបណ្ណបើកបរ ដែលចេញដោយស្ថាប័នមានសមត្ថកិច្ច ។

**ខ**- អ្នកប្រើប្រាស់នាវានេសាទ មិនត្រូវ :

១-ធ្វើនេសាទដែលប៉ះពាល់ ឬរំខានដល់ការធ្វើចរាចរផ្លូវទឹក ។

២-ធ្វើអាជីវកម្មនេសាទខុសទីតាំង ដែលបានកំណត់ក្នុងលិខិតអនុញ្ញាតឱ្យធ្វើអាជីវកម្មនេសាទ ។

៣-ធ្វើនាវាចរណ៍ឆ្លងកាត់ ឬធ្វើសកម្មភាពផ្សេងៗទៀត នៅក្នុងកន្លែងអភិរក្សជលផល ។

៤-ធ្វើនេសាទប្រើឧបករណ៍នេសាទដោយគ្មានការអនុញ្ញាត ។

៥-ដឹកជញ្ជូន ប្រមូលប្រភេទផល ផលិតផលជលផលពីធម្មជាតិដែលកំពុងរងគ្រោះថ្នាក់ ។

៦-ដឹកជញ្ជូនអុសធ្យូងប្រភេទឈើព្រៃលិចទឹក និងព្រៃកោងកាងជាលក្ខណៈអាជីវកម្ម ឬពាណិជ្ជកម្ម ។

៧-ចាប់ ដឹកជញ្ជូនកូន ឬពងត្រី និងកូន ឬពងវារីសត្វផ្សេងទៀតដោយគ្មានលិខិតអនុញ្ញាត ។

៨-ចូលសំចតនាវា ឬបោះយុថ្កានៅក្នុងតំបន់ផ្កាថ្មដោយគ្មានការអនុញ្ញាត ។

**ប្រការ ៦** : ការទិញ ការលក់ ការជួលនាវានេសាទ ការបាត់បង់ គ្រោះថ្នាក់ ឬប្តូរមុខរបរនេសាទ ត្រូវជូនដំណឹងដល់មន្ត្រីជលផលមានសមត្ថកិច្ច ។

**ប្រការ ៧** : អ្នកប្រើប្រាស់នាវានេសាទ ដែលប្រព្រឹត្តផ្ទុយនឹងខ្លឹមសារនៃប្រកាសនេះ ត្រូវផ្តន្ទាទោសតាមច្បាប់ជាធរមាន ។

**ប្រការ ៨** : ប្រកាស ឬសេចក្តីសម្រេចទាំងឡាយណាដែលផ្ទុយនឹងប្រកាសនេះ ត្រូវទុកជានិរាករណ៍ ។

**ប្រការ ៩** : អគ្គលេខាធិការ អគ្គាធិការ នាយកខុទ្ទកាល័យ ប្រធាននាយកដ្ឋាននីតិកម្មកសិកម្ម ប្រធាននាយកដ្ឋានកិច្ចការរដ្ឋបាល ប្រធាននាយកដ្ឋានផែនការ និងស្ថិតិ ប្រធាននាយកដ្ឋានគណនេយ្យ ហិរញ្ញវត្ថុ ប្រធានរដ្ឋបាលជលផល ត្រូវទទួលបន្ទុកអនុវត្តប្រកាសនេះ ឱ្យមានប្រសិទ្ធភាពតាមភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ ថ្ងៃទី ១៨ ខែ មករា ឆ្នាំ ២០១០

**រដ្ឋមន្ត្រី**

ចាន់ សារុន

**កន្លែងទទួល**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ទីស្តីការគណៈរដ្ឋមន្ត្រី
- ខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោនាយករដ្ឋមន្ត្រី
- ក្រសួងមហាផ្ទៃ
- ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- ក្រសួងយុត្តិធម៌
- ក្រសួងសាធារណការ និងដឹកជញ្ជូន
- សាលារាជធានី-ខេត្តពាក់ព័ន្ធ
- ដូចប្រការ ៩ " ដើម្បីអនុវត្ត "
- ឯកសារ-កាលប្បវត្តិ